DANCHURCHAID
AYUDA DE DCA
DENMARK
actalliance

WWW.DANCHURCHAID.ORG/ANTI-CORRUPTION



# DANCHURCHAID
# គោលនយោបាយប្រឆាំងអំពើពុករលួយរបស់

# គោលនយោបាយប្រឆាំងអំពើពុករលួយរបស់ DANCHURCHAID

គោលដៅរបស់គោលនយោបាយប្រឆាំងអំពើពុករលួយនេះគឺសម្រាប់និយោជិតរបស់ **DANCHURCHAID** ទាំងអស់។ ក្នុងនាមជានិយោជិតរបស់ DanChurchAid យើងមានកាតព្វកិច្ចក្នុងការគោរពតាមគោលនយោបាយប្រឆាំងអំពើពុករលួយនេះ ហើយប្រសិនបើមានការរំលោភបំពានលើគោលនយោបាយនេះត្រូវតែរាយការណ៍តាមរយៈយន្តការបណ្តឹងរបស់ DanChurchAid (មានបញ្ជាក់ខាងក្រោម)។

អំពើពុករលួយគំរាមកំហែងដល់អភិបាលកិច្ចល្អ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នីតិវិធីប្រជាធិបតេយ្យ និងការធ្វើជំនួញដោយស្មើភាព។ ដូចនេះការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយគឺជាការកសាងសង្គមស៊ីវិល និងការលុបបំបាត់អយុត្តិធម៌សង្គមដែលត្រូវគ្នាជាមួយនឹងទស្សនៈវិស័យរបស់ DanChurchAid ដែលចែងថា *"ដើម្បីជួយ និងធ្វើការតស៊ូមតិសម្រាប់ក្រុមដែលត្រូវបានគេគាបសង្កត់ មិនយកចិត្តទុកដាក់ដើម្បីឲ្យមានជីវិតប្រកបដោយភាពថ្លៃថ្នូរ"*។

បើយោងតាមចំណាត់ថ្នាក់អំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ ប្រទេសទាំងឡាយដែល DanChurchAid កំពុងតែប្រតិបត្តិការគឺសុទ្ធសឹងតែជាប្រទេសដែលមានហានិភ័យខ្ពស់ចំពោះអំពើពុករលួយនៅក្នុងពិភពលោក។ DanChurchAid ត្រូវតែធានាថាថវិកាជំនួយដែលខ្លួនបានចាត់ចែងនឹងមិនខុសគោលដៅទេ។

DanChurchAid ត្រូវបានគេផ្តល់ថវិកាពីប្រភពម្ចាស់ជំនួយជាច្រើន ហើយត្រូវធ្វើការដើម្បីធានាថាថវិកាទាំងនោះនឹងត្រូវចំណាយយ៉ាងត្រឹមត្រូវ និងប្រកបដោយតម្លាភាព។[1] DanChurchAid មានការទទួលខុសត្រូវខ្ពស់ក្នុងការចៀសវាងអំពើពុករលួយ និងធានាថាថវិកាជំនួយទាំងអស់ត្រូវបានចំណាយយ៉ាងត្រឹមត្រូវចំពោះមុខម្ចាស់ជំនួយ ដៃគូការងារ និងអ្នកទទួលផលទាំងឡាយ។

ក្នុងនាមជានិយោជិតរបស់ DanChurchAid យើងមានការទទួលខុសត្រូវក្នុងការការគាំទ្រ និងលើកកំពស់នូវសីលធម៌ និងការបំពេញការងារប្រកបដោយស្តង់ដាខ្ពស់បំផុត។ នៅក្នុងការបំពេញការងារនៅក្នុងប្រទេសផ្សេងៗគ្នាជាច្រើន ហើយពេលខ្លះក្នុងស្ថានភាពលំបាក និងមានភាពស្មុគ្រស្មាញ ក្នុងចំណោមភាសា វប្បធម៌ និងសាសនាខុសៗគ្នា យើងត្រូវការនូវការគាំទ្រច្រើនពីនិយោជិត។ ចំណេះដឹង

---

[1] ទស្សនៈវិស័យ និងផែនការ: អនុវត្តបំណង C: "*ដើម្បីធានាដល់ការចាត់ចែងដោយត្រឹមត្រូវ និងប្រកបដោយតម្លាភាពនូវធនធានហិរញ្ញវត្ថុដែលត្រូវបានប្រគល់ឲ្យ DanChurchAid".*

ការគោរព និងការយោគយល់គ្នាគឺជាពាក្យគន្លឹះមួយចំនួនក្នុងចំណោមពាក្យគន្លឹះទាំងឡាយក្នុងការដឹកនាំការងាររបស់យើង។

គោលបំណងរបស់គោលនយោបាយប្រឆាំងអំពើពុករលួយនេះគឺដើម្បីគាំទ្រដល់ការប្រព្រឹត្តទាំងឡាយដែលមានស្តង់ដាសុច្ចរិតភាពជាលក្ខណៈបុគ្គល និងអង្គការខ្ពស់ទាំងក្នុងអង្គការ និងជាមួយនឹងដៃគូខាងក្រៅដទៃទៀត (ដៃគូការងារ)។

## លក្ខណៈទូទៅ

អំពើពុករលួយគឺជា *ការប្រើប្រាស់នូវអំណាចដែលត្រូវបានប្រគល់ឲ្យមិនត្រឹមត្រូវដើម្បីភាពចំណេញរបស់បុគ្គល*។ គេស្គាល់អំពើពុករលួយជាទូទៅថាជាការផ្តល់សំណូក ការគេងបន្លំ ការបំភ័ន និងការទារជំរិត ហើយឧទាហរណ៍មួយចំនួននឹងមានរៀបរាប់លម្អិតខាងក្រោម។

អំពើពុករលួយមានជាច្រើនរូបភាព។ វាអាចស្ថិតនូវក្នុងរូបភាពជាថវិកា ឬការផ្តល់សេវាកម្មដើម្បីទទួលផលចំណេញដូចជាការយកចិត្តទុកដាក់ល្អ ការការពារពិសេស ការផ្តល់សេវាបន្ថែម ឬការពន្យាពេលជាដើម។ ជាការសំខាន់ណាស់ដែលយើងត្រូវដឹងថាអំពើពុករលួយមិនមែនសុទ្ធសឹងតែទាក់ទងទៅនឹងរឿងថវិកាមួយមុខនោះទេ។ ការផ្តល់ការងារឲ្យនរណាម្នាក់ធ្វើ ការផ្តល់សេវាកម្មដល់នរណាម្នាក់ ឬផ្តល់នូវជំនួយដទៃទៀត ក៏អាចចាត់ទុកជាអំពើពុករលួយបានផងដែរនៅក្នុងកាលៈទេសៈមួយចំនួន។

សុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួនមិនគួរត្រូវបានធ្វើការសម្របសម្រួលដើម្បីឲ្យស្របទៅនឹងគោលនយោបាយនេះទេ។

ក្នុងនាមជានិយោជិតរបស់ DanchurchAid យើងទទួលខុសត្រូវក្នុងការដើរតាម និងគោរពតាមច្បាប់ និងបទបញ្ញាផ្សេងៗរបស់ជាតិ និងអន្តរជាតិ។ ជាងនេះទៅទៀត យើងត្រូវតែគោរពអនុសញ្ញាអន្តរជាតិផ្សេងៗដែលប្រទេសដែលយើងធ្វើប្រតិបត្តិការបានចុះហត្ថលោខាផ្តល់សច្ចាប័ន។

DanchurchAid ទទួលខុសត្រូវក្នុងការជំរាបដល់អង្គការដៃគូ និងអ្នកដែលពាក់ព័ន្ធដទៃទៀតអំពីគោលនយោបាយនេះ។

## គោលការណ៍ប្រឆាំងអំពើពុករលួយ

ខាងក្រោមនេះគឺជាបញ្ជីនៃគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ DanchurchAid ។

1. ជម្លោះផលប្រយោជន៍
2. ការរំលោភអំណាច និងការជំរិត
3. ការបំភ័ន ការគេងបន្លំ
4. សំណូក
5. បក្សពួកនិយម
6. អំណោយផ្សេងៗ

## 1. ជម្លោះផលប្រយោជន៍

*យើងនឹងជៀសវាងនូវជម្លោះផលប្រយោជន៍ដែលមិនត្រឹមត្រូវ ទោះបីជាការពិត ឬអាចនឹងកើតមានឡើងក៏ដោយ រវាងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់យើង និងផលប្រយោជន៍របស់ DanChurchAid ។*

ការជៀសវាងនូវជម្លោះផលប្រយោជន៍គឺជាគោលការណ៍រួមនៅក្នុងការប្រឆាំងអំពើពុករលួយ។ ជម្លោះផលប្រយោជន៍កើតមានឡើងស្ថានភាពទាំងឡាយដែលលោក លោកស្រី នាងកញ្ញាក្នុងនាមជានិយោជិតរបស់ DanChurchAid មានផលប្រយោជន៍ឯកជនដែលអាចជះឥទ្ធិពលដល់ការធ្វើការងារប្រកបដោយវិជ្ជាជីវៈរបស់លោកអ្នក។

ជម្លោះផលប្រយោជន៍អាចកើតមានឡើងញឹកញាប់ ប៉ុន្តែមិនសុទ្ធសឹងតែជាអំពើពុករលួយនោះទេ ដូច្នេះអ្វីដែលសំខាន់នោះគឺយើងត្រូវកំណត់ និងចាត់ចែងនូវជម្លោះផលប្រយោជន៍នេះយ៉ាងដូចម្តេច។ ប្រសិនបើជម្លោះផលប្រយោជន៍មិនត្រូវបានកំណត់ និងចាត់ចែងបានត្រឹមត្រូវនោះទេ វាអាចធ្វើឲ្យអន្តរាយដល់សុច្ចរិតភាពរបស់ DanChurchAid និងជាលទ្ធផលគឺអំពើពុករលួយ។ យើងរំពឹងថានិយោជិតមួយរូបៗមានសុភវិនិច្ឆ័យ ហើយប្រសិនបើមានការមន្ទិលសង្ស័យត្រូវតែធ្វើការទំនាក់ទំនងជាមួយប្រធានរបស់ខ្លួន។ ចំពោះសំណួរទាំងឡាយទាក់ទងទៅនឹងជម្លោះផលប្រយោជន៍ ជាការសំខាន់ណាស់ដែលយើងត្រូវប្រើនូវការវិនិច្ឆ័យផ្ទាល់ខ្លួន និងការយល់ជាទូទៅក្នុងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ។ គោលការណ៍ដូចខាងក្រោមនេះ គឺជាឧទាហរណ៍នៃជម្លោះផលប្រយោជន៍។

## 2. ការរំលោភអំណាច និងការជំរិត

*យើងនឹងមិនស្វែងរកដើម្បីបង្កើតជាឥទ្ធិពលដល់នរណាម្នាក់ ឬស្ថាប័នណាមួយក្នុងគោលបំណងឯកជន តាមរយៈការប្រើប្រាស់តួនាទីរបស់យើង ឬផ្តល់ពួកគេនូវអត្ថប្រយោជន៍ផ្ទាល់ខ្លួនផ្សេងៗនោះទេ។ ដូចគ្នានេះដែរ យើងនឹងមិនប្រើប្រាស់សម្ភារៈ*

*ទីកន្លែង សេវាកម្ម និងធនធានថវិការបស់ DanChurchAid ក្នុងគោលបំណងឯកជន លើកលែងតែមានការអនុញ្ញាតឲ្យធ្វើដូចនោះ។ យើងមិនប្រើប្រាស់នូវការជំរិតទោះបីជាក្នុងទម្រង់ណាក៏ដោយ ជាវិធីសាស្ត្រក្នុងការទទួលបាននូវគុណសម្បត្តិនោះទេ។*

គោលការណ៍នេះបញ្ជាក់ថា លោក លោកស្រី នាងកញ្ញាមិនគួរប្រើប្រាស់នូវឋានៈផ្ទាល់ខ្លួនដើម្បីផលចំណេញឯកជននោះទេ។ ការប្រើប្រាស់មិនត្រឹមត្រូវអាចជាវិធីដើម្បីទទួលបានផលប្រយោជន៍ដែលយើងនឹងមិនទទួលបានប្រសិនបើមិនធ្វើដូចនេះ។ យើងមិនត្រូវប្រើប្រាស់ទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ដើម្បីទទួលបានការបញ្ចុះតម្លៃ ដូចជាកុំព្យូទ័រ ឡាន ម្ហូបអាហារ ការគាំទ្ររបស់ទីប្រឹក្សា ឬការធ្វើដំណើរក្នុងលក្ខណៈឯកជនឡើយ។ អ្នកក៏មិនត្រូវរំលោភអំណាចក្នុងនាមជាអ្នកគ្រប់គ្រងដើម្បីទទួលបានផលប្រយោជន៍ ឬសេវាកម្មផ្ទាល់ខ្លួនដែលធ្វើឡើងដោយនិយោជិតឡើយ។

## 3. ការបំភ័ន ការគេងបន្លំ

*ការបំភ័ន និងការគេងបន្លំគឺជាអំពើខុសច្បាប់ ហើយមិនត្រូវប្រើវាជាវិធីសាស្ត្រដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍ការងារ ឬទ្រព្យសម្បត្តិទាក់ទងទៅនឹង DanChurchAid អង្គការដៃគូ ឬដៃគូពាក់ព័ន្ធដទៃទៀតនោះទេ។*

ការបំភ័នគឺជាបទឧក្រិដ្ឋសេដ្ឋកិច្ចដែលទាក់ទងទៅនឹងការឆបោក ការប្រើល្បិច ឬការធ្វើជាពុត ដែលក្នុងនោះនរណាម្នាក់ទទួលបាននូវអត្ថប្រយោជន៍ ឬថវិកាជំនួយដោយមិនស្របច្បាប់។ ការគេងបន្លំគឺជាការប្រើប្រាស់នូវទ្រព្យសម្បត្តិ ឬថវិកាជំនួយដោយស្របច្បាប់ដែលត្រូវបានប្រគល់ឲ្យនរណាម្នាក់ដែលមានតំណែងផ្លូវការរបស់គេក្នុងនាមជាភ្នាក់ងារ ឬអ្នកមើលការថែទាំ។

ឧទាហរណ៍នៃការបំភ័ន និងការគេងបន្លំរួមមានការបន្លំឯកសារ ការកុហកពីលក្ខណៈសម្បត្តិ និងការរំលោភអំណាច/ចំណេះដឹងដើម្បីលួចសាច់ប្រាក់ និងទ្រព្យសម្បត្តិពីការិយាល័យ ការប្រើប្រាស់ប្រាក់ជំនួយមិនត្រឹមត្រូវដែលត្រូវបានប្រគល់ឲ្យយើង។

ដូចនេះវិធានផ្សេងៗទាក់ទងទៅនឹងការងារគណនេយ្យត្រូវតែគោរពតាមគ្រប់ពេលវេលាទាំងអស់។ ឧទាហរណ៍ ការផ្តល់ការយល់ព្រមលើការចំណាយត្រូវតែគោរពតាម "សៀវភៅគណនេយ្យការិយាល័យតំបន់របស់ DCA" ហើយការផ្តល់ការយល់ព្រម

លើកម្មវិធី និងគម្រោងផ្សេងៗត្រូវតែគោរពតាម "សៀវភៅកម្មវិធី និងគម្រោង" (PPM) ។ យើងរំពឹងថាគ្រប់លំនាំទាំងអស់ត្រូវតែបង្ហាញពីភាពស្មោះត្រង់។

## 4. សំណូក

*យើងនឹងមិនផ្តល់ឲ្យ ឬទទួលយកនូវសំណូកទោះបីជាក្នុងរូបភាពណាក៏ដោយ។*

សំណូកគឺជាអំពើផ្តល់លុយ សេវាកម្ម ឬវត្ថុមានតម្លៃដល់នរណាម្នាក់ដើម្បីបញ្ចុះបញ្ចូលគេឲ្យធ្វើអ្វីមួយឲ្យយើងវិញ។ (សំណូកក៏អាចហៅបានថា ថវិកាផ្តល់ដោយខុសច្បាប់ដើម្បីឲ្យគេជួយ ឬធ្វើការឲ្យ (kickback) ថវិកាតិចតួចឲ្យជាអំណោយដល់អ្នកក្រីក្រ (baksheesh) ការផ្តល់ប្រាក់ដើម្បីឲ្យនរណាម្នាក់ធ្វើអ្វីមួយខុសច្បាប់ (payola) ការផ្តល់លុយដើម្បីកុំឲ្យនរណាម្នាក់ផ្តល់ពត៌មានដល់អ្នកដទៃ (hush money) ការផ្តល់អ្វីមួយដល់នរណាម្នាក់ដើម្បីបញ្ចុះបញ្ចូលឲ្យធ្វើអ្វីមួយសម្ងាត់ (sweetener) ថវិកាការពារ (protection money) លុយពុករលួយ (boodle) លុយទឹកតែ (gratuity)[2])។

ឧទាហរណ៍ យើងមិនទទួលយកសំណូកពីដៃគូដើម្បីរៀបចំកិច្ចសន្យាជាមួយពួកគេ ហើយយើងក៏មិនផ្តល់សំណូកដល់ដៃគូរបស់យើងដើម្បីជាវិធីមួយដែលធ្វើឲ្យមានឥទ្ធិពលដល់ដៃគូដែរ។ យើងធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូរបស់យើងដោយ

---

[2] *ការបង់លុយដើម្បីសម្រួលការងារ:* ការបង់ប្រាក់ដើម្បីសម្រួលការងារគឺជាបង់ប្រាក់តិចតួចដល់មន្ត្រីសាធារណៈ ឬមន្ត្រីដទៃទៀតដើម្បីឲ្យធ្វើការឲ្យបានលឿន ឬដើម្បីធ្វើការងារ ឬចាត់វិធានការធម្មតា។ ការធ្វើការងារធម្មតានៅទីនេះត្រូវបានផ្តល់និយមន័យជាសកម្មភាពទាំងឡាយណាដែលជាការងារ ឬមុខងារមួយផ្នែកប្រចាំថ្ងៃរបស់បុគ្គលិកយើង។ DanChurchAid ប្រឆាំងយ៉ាងខ្លាំងក្លាដល់ការបង់ប្រាក់ដើម្បីសម្រួលការងារ ហើយការបង់ប្រាក់បែបនេះមិនត្រូវធ្វើឡើងឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ DanChurchAid ទទួលស្គាល់ថាយើងធ្វើការនៅក្នុងផ្នែកទាំងឡាយនៃពិភពលោកដែលមានការលំបាកណាស់ក្នុងការចៀសវាងនូវការចំណាយបែបនេះ។ ការបង់ប្រាក់ដើម្បីសម្រួលដល់ការងារត្រូវតែរៀបចំជាឯកសារដោយមានវិក័យប័ត្រ និងត្រូវតែធ្វើរបាយការណ៍ដោយប្រើយន្តការបណ្តឹង (ដូចគ្នាទៅនឹងការរំលោភបំពានលើគោលនយោបាយប្រឆាំងអំពើពុករលួយដែរ)។ ការធ្វើបែបនេះដើម្បីធានាដល់តម្លាភាព និងការទទួលខុសត្រូវ និងដើម្បីរៀនពីឧទាហរណ៍ទាំងនេះ ដែលអាចធ្វើឲ្យ DanChurchAid អាចជៀសវាងនូវស្ថានភាពប្រហាក់ប្រហែលគ្នានេះដែរនៅពេលអនាគត។

ផ្អែកទៅលើភាពជាម្ចាស់ការទៅវិញទៅមក ការទទួលខុសត្រូវ ការចូលរួម ស្មើភាព សុខដុមភាវូបនីយកម្ម និងការតម្រង់ (គោលនយោបាយភាពជាដៃគូរបស់ DanChurchAid ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ)

សំណូកគឺជាអំពើខុសច្បាប់នៅគ្រប់ប្រទេសទាំងអស់ ហើយធ្វើឲ្យមានគ្រោះថ្នាក់ដល់ឱកាសក្នុងការប្រកួតប្រជែងប្រកបដោយស្មើភាព ហើយវាក៏បង្កើតនូវទីផ្សារជំនួញដែលគ្មានតម្លាភាពដែលមានការលំបាក ឬមិនអាចធ្វើទៅបាន។

**5. បក្សពួកនិយម**

*យើងនឹងមិនយោគយល់មិត្តភ័ក្រ គ្រួសារ ឬការទំនាក់ទំនងជាលក្ខណៈបុគ្គលនៅក្នុងការជ្រើសរើស លទ្ធកម្ម ការចែកចាយអំណោយ ឬក្នុងស្ថានភាពដទៃទៀតទេ។*

បក្សពួកនិយមគឺជាគឺជាអនុគ្រោះចំពោះសាច់ញាតិ និងមិត្តភ័ក្រដោយផ្អែកទៅលើការទំនាក់ទំនងជាជាងការវាយតម្លៃដោយផ្អែកទៅលើសមត្ថភាព ឬភាពសមស្រប។ ឧទាហរណ៍ ការផ្តល់ការងារដល់សាច់ញាតិ ឬមិត្តភ័ក្រ ទោះបីជាមានអ្នកដទៃទៀតដែលមានសមត្ថភាពជាង និងមានឆន្ទៈក្នុងការបំពេញការងារ ការផ្តល់ប្រាក់ខែច្រើន និងផលប្រយោជន៍ដទៃទៀតដល់និយោជិតដែលជាសាច់ញាតិរបស់គណៈគ្រប់គ្រងជាដើម។

ដើម្បីជៀសវាងបក្សពួកនិយមនៅក្នុងលទ្ធកម្ម យើងត្រូវគោរពតាមសៀវភៅលទ្ធកម្មរបស់ DanChurchAid សូមមើលគេហទំព័ររបស់ DCA:

http://www.danchurchaid.org/procurement/dca_procurement_manual_3rd_edition.

នៅក្នុងការជ្រើសរើសបុគ្គលិកនៅការិយាល័យតំបន់ យើងគោរពតាម "គោលនយោបាយជ្រើសរើសបុគ្គលិកជាតិ" របស់ DanChurchAid ហើយនៅក្នុងការជ្រើសរើសបុគ្គលិកនៅការិយាល័យកណ្តាល យើងគោរពតាមគោលនយោបាយជ្រើសរើស។

ជាការសំខាន់ណាស់ដែលយើងត្រូវគូសបញ្ជាក់ថា ប្រសិនបើអាចដោះស្រាយពីជម្លោះផលប្រយោជន៍បាន យើងអាចទទួលយកបាននៅក្នុងការជួល/ធ្វើការជាមួយគ្រួសារ ឬមិត្តភ័ក្រ។

**6. អំណោយ**

*យើងនឹងមិនផ្តល់ ឬទទួល ទោះជាដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ឬការអនុគ្រោះដទៃទៀត ដែលអាចជះឥទ្ធិពលដល់ការអនុវត្តមុខងារ ការធ្វើការរបស់យើង ឬវិធីដទៃទៀតដែលអាចមានគ្រោះថ្នាក់ដល់ DanChurchAid ឡើយ។ អំណោយត្រូវបានផ្តល់ជានិយមន័យថាជាសេវាកម្ម ការធ្វើដំណើរ ការផ្តល់ការកំសាន្ត ជារបស់របរ ឬការអនុគ្រោះផ្សេងៗ ប៉ុន្តែមិនកំណត់តែចំពោះលើចំណុចតែប៉ុណ្ណោះនោះទេ។ ដើម្បីគោរពប្រពៃណីក្នុងស្រុក និងការទទួលភ្ញៀវជាទូទៅ អំណោយតិចតួចអាចទទួលយកបាន។*

តម្លៃរបស់អំណោយអាចទទួលយកបានមានការខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតដែល DanChurchAid ធ្វើការ។ អំណោយជាសាច់ប្រាក់មិនអាចទទួលយកបានទេ។ និយោជិតគ្រប់រូបត្រូវបានរំពឹងថានឹងបង្ហាញនូវសុភវិនិច្ឆ័យ ហើយប្រសិនបើមានមន្ទិល ត្រូវទាក់ទងជាមួយអ្នកគ្រប់គ្រង។ វិធានដ៏ងាយនោះគឺធ្វើយ៉ាងដូចម្តេចកុំឲ្យអំណោយដែលគេឲ្យអាចជះឥទ្ធិពលដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យភាព និងសូមចែករំលែកអំណោយដែលអ្នកទទួលនោះជាមួយនឹងសហការីរបស់អ្នក។

## យន្តការបណ្តឹងរបស់ DanChurchAid

ក្នុងនាមជានិយោជិតរបស់ DanChurchAid យើងមានភារកិច្ចក្នុងការគោរពតាមគោលនយោបាយប្រឆាំងអំពើពុករលួយនេះ និងរាយការណ៍នូវការរំលោភបំពានផ្សេងៗលើគោលនយោបាយនេះ។ គ្រប់ហេតុការណ៍ពុករលួយនៅក្នុង DanChurchAid អង្គការដៃគូ ឬហេតុការណ៍ដទៃទៀតដែលទាក់ទងទៅនឹងសកម្មភាពទាំងឡាយរបស់ DanChurchAid ត្រូវតែរាយការណ៍នៅក្នុងយន្តការបណ្តឹង។ ប្រសិនបើអ្នកមានការសង្ស័យ ឮពាក្យចចាមអារាមទាក់ទងទៅនឹងអំពើពុករលួយ ឬជួបប្រទះនូវមន្ទិលសង្ស័យ អ្នកក៏អាចស្នើសុំនូវតំបូន្មាននៅទីនេះបានផងដែរ។

អ្នកតត្រូវបំពេញទម្រង់ពាក្យបណ្តឹង និងផ្ញើទៅកាន់ :

- ប្រអប់ចាក់សោរសម្រាប់ទទួលពាក្យបណ្តឹងដែលដាក់នៅទ្វារចូលការិយាល័យ DCA/CA ទីក្រុងភ្នំពេញ ឬ
- សេវាកម្មផ្ញើសំបុត្រទៀងទាត់ (សូមមើលអាស័យដ្ឋាន និងទំនាក់ទំនង) ឬ
- ផ្ញើសារអេឡិចត្រូនិចទៅកាន់ complaints.cambodia@dca.dk ឬ

- ផ្ញើសារអេឡិចត្រូនិចទៅកាន់complaint@dca.dk ។ មានតែបុគ្គលិកបីរូប ប៉ុណ្ណោះមកពីផ្នែកធនធានមនុស្សនៅទីក្រុង Copenhagen ដែលអាច មើលអាស័យដ្ឋានសារអេឡិចត្រូនិចទាំងនេះ។ ពាក្យបណ្តឹងនីមួយៗ នឹងត្រូវធ្វើការពិចារណាថាតើត្រូវបង្កើតគណៈកម្មាធិការស៊ើបអង្កេត ហើយត្រូវធ្វើការស៊ើបអង្កេតឬយ៉ាងណា។

ពាក្យបណ្តឹងនឹងត្រូវដោះស្រាយដោយរក្សាការសម្ងាត់ និងដោយក្តីគោរព ចំពោះអ្នកប្តឹង និងបុគ្គល/អង្គការទាំងឡាយដែលពាក្យបណ្តឹងនេះកំពុងតែធ្វើការចោទ ប្រកាន់។ ពាក្យបណ្តឹងដែលគ្មានឈ្មោះនឹងមិនទទួលយកទេ។ គ្រប់ហេតុការណ៍ទាក់ ទងទៅនឹងអំពើពុករលួយទាំងអស់ត្រូវតែរាយការណ៍នៅក្នុងយន្តការបណ្តឹង ដោយរួម បញ្ចូលទាំងករណីទាំងឡាយណាដែលមានការស៊ើបអង្កេតជាលក្ខណៈតំបន់ផងដែរ។ ករណីទាំងឡាយណាដែលអាចបង្កជាគ្រោះថ្នាក់ដល់បុគ្គលក៏ត្រូវរាយការណ៍នៅក្នុង យន្តការបណ្តឹងផងដែរ។

យន្តការបណ្តឹងអាចមើលបានតាមរយៈគេហទំព័ររបស់ DanChurchAids: http://www.danchurchaid.org/contacts/complaints ។

## របាយការណ៍ពុករលួយប្រចាំឆ្នាំ និងរបាយការណ៍ពុករលួយ

"របាយការណ៍ប្រឆាំងអំពើពុករលួយ" ប្រចាំឆ្នាំគឺជាការប៉ុនប៉ងមួយដើម្បីសង្ខេប ពីអ្វីដែល DanChurchAids ធ្វើដើម្បីប្រឆាំង និងការពារអំពើពុករលួយដោយវិធីហិរញ្ញ វត្ថុចាត់ចែងដោយ DanChurchAids ។ របាយការណ៍នេះបោះពុម្ពជារៀងរាល់ឆ្នាំនៅ លើគេហទំព័ររបស់ DanChurchAids ជាមួយនឹងរបាយការណ៍ប្រចាំឆ្នាំ។

"របាយការណ៍ពុករលួយ" ត្រូវបានបោះពុម្ពនៅលើគេហទំព័ររបស់ DanChurchAids និងធ្វើបច្ចុប្បន្នភាពក្នុងរយៈពេល 48 ម៉ោង។ របាយការណ៍នេះរៀប រាប់យ៉ាងលម្អិតករណីពុករលួយ និងការគេងបន្លំដែល DanChurchAids បានធ្វើការ ដោះស្រាយ។ រឿងរ៉ាវដែលទាក់ទងទៅនឹងបុគ្គលនឹងមិនធ្វើការបោះពុម្ពទេ។

គោលបំណងនៃការបោះពុម្ពនេះគឺដើម្បីជម្រាបជាសាធារណៈអំពីបញ្ហាទាំង ឡាយដែលពិនិត្យលើអំពើពុករលួយនៅក្នុងប្រទេសដែលយើងធ្វើការ និងដើម្បីរៀប រាប់ពីវិធីដែលយើងដោះស្រាយបញ្ហា និងការពារបញ្ហាមិនឲ្យកើតមានពេលអនាគត។

របាយការណ៍ទាំងឡាយ និងឯកសារ និងពត៌មានទាក់ទងទៅនឹងការប្រឆាំង អំពើពុករលួយដទៃទៀតមានៅក្នុងគេហទំព័ររបស់ DanChurchAids : www.danchurchaid.org/anti-corruption